**១. សមាសភាពសិក្សាស្រាវជ្រាវ**

- លោក ហ៊ីង ប៊ុនណាត អ្នកដឹកនាំការស្រាវជ្រាវ
- លោក យុត ឃីម ជំនួយការដឹកនាំការស្រាវជ្រាវ
- លោក លី ជី ជំនួយការសិក្សាស្រាវជ្រាវ
- លោក ឡាច ចំរើន ជំនួយការសិក្សាស្រាវជ្រាវ

**២. សមាសភាពចូលរួមផ្តល់យោបល់ និងខ្លឹមសារអត្ថបទ**

- លោកពូ រស់ លីម អ្នកដឹកនាំសហគមន៍ក្អួយ ភូមិបង្កើនផល
- លោក ទន់ មាន អ្នកដឹកនាំសហគមន៍ក្អួយ ភូមិត្រពាំងទន្ទឹម
- លោកពូ អ៊ុន វី អ្នកដឹកនាំសហគមន៍ក្អួយ ភូមិរំចេក
- លោកអ៊ុំ ហ៊ុត សាវី ចាស់ស្រុកនៅសហគមន៍ក្អួយ ភូមិក្រាំងដូង
- លោកអ៊ុំ ទុយ ឆេង ចាស់ស្រុកនៅសហគមន៍ក្អួយ ភូមិរំដេង

**៣. តំណាងសហគមន៍ដែលបានចូលរួមផ្តល់យោបល់**

- តំណាងសហគមន៍ក្អួយ ភូមិភ្នាក់រលឹក
- តំណាងសហគមន៍ក្អួយ ភូមិផ្អា
- តំណាងសហគមន៍ក្អួយ ភូមិសំរោង
- តំណាងសហគមន៍ក្អួយ ភូមិតស៊ូ
- តំណាងសហគមន៍ក្អួយ ភូមិប្រើសក្អក
- តំណាងសហគមន៍ក្អួយ ភូមិប្រមេរ
- តំណាងសហគមន៍ក្អួយ ភូមិប៉ាលហាល

**៤. ជំនួយការបកប្រែភាសាបរទេស**

- ក្រុមការងារបច្ចេកទេស ភូមិអាស៊ី (ខេត្តកំពង់ធំ)
- លោក ហ៊ីង ប៊ុនណាត

៥. សម្របសម្រួល និងចងក្រង

- លោក ហ៊ីង ប៊ុនណាត

រក្សាសិទ្ធិដោយ OPKC

| មាតិការ | ទំព័រ |
|---|---|


1. សេចក្ដីផ្ដើម ....3
- បុព្វហេតុ ....3
- គោលបំណង ....3
- ខ្លឹមសា ....3

2. ពាក្យតាមអក្សរ ....4
- អក្សរក ....4-6
- អក្សរខ ....6
- អក្សរគ ....7-8
- អក្សរឃ ....8
- អក្សរង ....8
- អក្សរច ....9
- អក្សរឆ ....10
- អក្សរជ ....11-12
- អក្សរឈ ....13
- អក្សរញ ....13
- អក្សរដ ....14-15.
- អក្សរត ....15-21
- អក្សរប ....21-28
- អក្សរព ....28-30
- អក្សរវ ....30-32
- អក្សរស ....32-33
- អក្សរអ ....33-36


រក្សាសិទ្ធិដោយ OPKC

# ១. សេចក្តីផ្តើម

## ១.១. បុព្វហេតុ

អង្គការលើកស្ទួយវប្បធម៌កួយ តាមរយៈកម្មវិធីចំណេះដឹងនិងសហគមន៍ បានអនុវត្តគម្រោងស្តីពី **"ការលើកកម្ពស់ភាសាដើមកួយ និងភាពអង់អាចសហគមន៍"** ក្រោមមូលនិធិពី VOICE។ គម្រោងបានសហការជាមួយអាជ្ញាធរ និងយុវជនជាជនជាតិកួយក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ ព្រមទាំងខេត្តមួយចំនួនទៀតចាប់ពីខែមេសាឆ្នាំ២០២២ដល់ខែមេសាឆ្នាំ២០២៤។ បញ្ហាដែលបានរកឃើញ អង្គការលើកស្ទួយវប្បធម៌កួយបានចងក្រងក្រុមការងារសហគមន៍កួយបន្តការសិក្សាស្រាវជ្រាវ ចងក្រងភាសារកួយបុរាណ និងពាក្យកួយបច្ចុប្បន្ន។ អក្សរជនជាតិដើមភាគតិចកួយបានបាត់បង់ដោយនៅសល់តែរឿងនិទានតៗគ្នា។ ភាសាកួយត្រូវបានប្រមូលចងក្រងដើម្បីធ្វើជាសៀវភៅ វចនានុក្រម រក្សាទុកតាមអែប គេហទំព័រ និងប្រព័ន្ធសង្គម។ សហគមន៍ជនជាតិដើមភាគតិចកួយដែលស្ថិតក្នុងតំបន់ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច និងសម្បទានរ៉ែ បានបន្លឺសម្លេងរបស់ខ្លួនអំពីការប្រើប្រាស់សិទ្ធិតាមយរៈការនិយាយភាសាដើមអត្តសញ្ញាណត្រូវបានយកចិត្តទុកដាក់ឡើងវិញដោយយុវជន។

គោលបំណង

## ១,២, ខ្លឹមសារៈ

អង្គការលើកស្ទួយវប្បធម៌កួយ (OPKC) បានពង្រឹងការនិយាយភាសាកួយឡើងវិញ ដោយផ្តើមចេញពីជនជាតិកួយខ្លួនឯងតាមរយៈក្រុមប្រពៃណី ក្រុមសហគមន៍ដែលបានចងក្រង និងសកម្មភាពផ្សារភ្ជាប់រវាងចាស់ទុំនិងយុវជន។ សហគមន៍កួយបានទំនាក់ទំនងគ្នាជាភាសាកួយពីតំបន់មួយទៅតំបន់មួយតាមរយៈការផ្ទេរចំណេះដឹង និងទំនាក់ទំនងព័ត៌មានសង្គម។ ក្រុមសកម្មគិតគូរសហគមន៍(ATTGs)ត្រូវបានចងក្រងនៅតាមខេត្ត។ ក្រុមអប់រំយុវជនកួយ(ETTGs) ត្រូវបានចងក្រងឡើងផ្តោតលើសកម្មភាពចូលរួមចងក្រងភាសាកួយ ការរៀនភាសាកួយ និងការបង្រៀនភាសាកួយ។

## ១.៣. គោលបំណង

គម្រោងមានគោលដៅ ដើម្បីលើកកម្ពស់ភាសាជនជាតិដើមភាគតិចកួយ តាមរយៈវចនានុក្រមកម្មវិធីពហុភាសា និងការពង្រឹងភាពអង់អាចសហគមន៍កួយ អមដោយគោលបំណងរួមចំនួនពីរគឺៈ ទីមួយៈបង្កើនចំណេះដឹងពីភាពអង់អាចរបស់សហគមន៍កួយ តាមរយៈការពង្រឹងការភាពអង់អាចដល់សហគមន៍កួយ ក្នុងការកសាងបណ្តាញសកម្មដោយមានក្រុមការងារសហគមន៍កួយធ្វើសកម្មភាពរួមគ្នា។ ទីពីរៈការពង្រឹងពហុភាសាជនជាតិកួយតាមរយៈការផ្សព្វផ្សាយវចនានុក្រមពហុភាសាកួយតាមរយៈការចងក្រង

OPKC

ពាក្យថ្មីនិងពាក្យពីបុរាណនិងធ្វើឲ្យមានតាមលំដាប់អក្ខរក្រមដាក់ក្នុងប្រព័ន្ធកម្មវិធីអនឡាញ និងការផ្សព្វផ្សាយវចនានុក្រម និងអក្ខរក្រមក្នុងពត៌មានសង្គមឲ្យកាន់តែមានសម្លេង។

## ២. ពាក្យតាមអក្សរក្រម

| ភាសាកួយ | ភាសាខ្មែរ | ភាសាអង់គ្លេស | ខ្លឹមសារ និងការបកស្រាយ |
|---|---|---|---|
| **អក្សរ ក** | | | |
| **កប ចៀង** *(តំបន់អ្វ៊)* **កោប ចៀង** *(តំបន់ក្រើ)*  | ទាក់ ឬចាប់ដំរី | Catch elephants | នៅតាមភូមិខ្លះ ជនជាតិកួយពីបូរាណ ត្រូវតែមានអ្នកចេះវិធី និងមានចំណេះដឹងខាងការទាក់ដំរីពីព្រៃយកទៅចិញ្ចឹមនៅស្រុក។ នៅមុនសម័យអាណានិគមបារាំង ជនជាតិកួយប្រើប្រាស់ចំណេះដឹងការទាក់ដំរីសម្រាប់ជាកម្លាំងអូសទាញដូចជា: ការអូសឈើធ្វើផ្ទះក្នុងភូមិ ការសាងសង់វត្តអារ៉ាម សាឡុំ ហារ ឬកុដក្នុងវត្ត ឬជិះដំរីជាមធ្យោបាយធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀត ឬជិះដំរីទៅចូលរួមពិធីបុណ្យ។ |
| **កន ចៅ**  | កូនចៅ | Descendant | សំដៅលើពាក្យដែលជនជាតិកួយ ប្រើនៅពេលដែលពួកគាត់និយាយទៅកាន់កូនចៅគាត់ ដោយពោលជារួមទៅលើកុមារាកុមារី និងយុវជនក្នុងការបង្ហាញពីការស្រឡាញ់ពេញចិត្ត ការផ្តល់ជំបូន្មាន ឬឲ្យយុវជននិងកុមារទាំងនោះចេះសាមគ្គីគ្នា។ ជាទូទៅចាស់ស្រុក ឬចាស់ទុំនិយាយទៅកាន់ក្មេងៗ ឬមនុស្សជំនាន់ក្រោយដោយបង្ហាញការផ្តល់សេចក្តីគោរព និងការអធ្យាស្រ័យនិស្ស័យកូនចៅ។ |
| **កោះ ក្មូច** | ព្រៃកប់សព | Cemetery | ពាក្យនេះ សំដៅដល់ព្រៃកប់ខ្មោច ឬព្រៃស្មសាន ដែលពីដើមឡើយជនជាតិកួយ នៅពេលដែលពួកគាត់បង្កើតភូមិមួយ ពួកគាត់ត្រូវរក្សាទុក |



ព្រៃស្របតាមទំហំជាក់ស្តែង ឬទំហំត្រៀមទុកពង្រីកសម្រាប់សមាជិកក្នុងភូមិដែលមរណៈកាល។ ពួកគាត់អនុវត្តការកប់សព ឬរំលាយសពនៅក្នុងព្រៃតែមួយ។ ជនជាតិកួយរក្សាទំហំដីព្រៃកប់សពដោយគិតពីកំណើនអ្នកភូមិ និងការរីកភូមិទៅពេលអនាគត។ ជនជាតិកួយប្រើប្រាស់ចំណេះដឹងប្រពៃណីរបស់ខ្លួនក្នុងការកប់សព ឬរំលាយសពដោយរៀបចំកិច្ចតាមប្រពៃណី ហើយមានអ្នកភូមិចូលរួមជួយគ្នា។

**ភន្ត្រៅ ភា**
*(តំបន់អ្វ៊)*
**បំបូល ភា**
*(តំបន់អ្រ្វើ)*



ទៅបំពុលត្រី

Go and poison fish

ពាក្យនេះ ត្រូវបានប្រើប្រាស់ដោយជនជាតិកួយពីបុរាណ គឺសំដៅទៅលើសកម្មភាពរបស់បុរសៗដែលមានកម្លាំង ហើយបានបបួលគ្នីគ្នាទៅរកផ្លែឈើ ឬផ្កាលដើម្បីយកទៅបុក ឬដំឲ្យហ្មត់នៅតាមមាត់អូរ ឬមាត់ប្រឡាយដែលមានអន្លង់ទឹកជ្រៅ និងមានត្រីច្រើន។ ក្រោយពីការបុក ឬដំឲ្យហ្មត ពួកគាត់អូសចុះអូសឡើងក្នុងទឹកដើម្បីធ្វើឲ្យទឹកល្អក់ហើយសារធាតុថ្នាំរលាយចូលទៅក្នុងទឹកអន្លង់ធ្វើឲ្យត្រីទាំងតូចទាំងធំពុល ប្រកាច់ ឬស្លាប់ ពេលនោះពួកគេងាយស្រួលក្នុងការចាប់ ឬត្រងយកត្រីបានងាយស្រួលហើយបន្ទាប់មកពួកគាត់ក៏យកទៅធ្វើជាម្ហូបអាហារ និងចែករំលែកដល់បងប្អូនក្នុងភូមិ។

**ភប ឆ្លៅ**
*(តំបន់អ្វ៊)*
**ភប ភ្លា**
*(តំបន់អ្រ្វើ)*

ចាប់សត្វខ្លា

Catch tigers

ពាក្យនេះសំដៅលើសកម្មភាពព្រានព្រៃដែលចេះវិធី ឬក្បួនចាប់ខ្លា។ នៅពេលដែលសត្វខ្លាអុកឡុក ឬចូលភូមិ ជនជាតិកួយពីបុរាណ បានបបួលគ្នីគ្នាធ្វើអង្គប់ដាក់យកសត្វខ្លា ដោយប្រើប្រាស់ចំណេះដឹង និងការសាមគ្គីគ្នា។ ពួកគាត់ធ្វើបែបនេះដើម្បីទប់ស្កាត់ការរាតត្បាតពីសត្វខ្លាដែលនឹងចូលភូមិធ្វើឲ្យអ្នកស្រុកខ្លាចរអារ ឬដើម្បីកុំឲ្យសត្វខ្លាស៊ីគោ



ស៊ីក្របីរបស់អ្នកស្រុក ឬកុំឲ្យមានការរំខានដល់អ្នកស្រុក ឬដើម្បីកុំអោយអ្នកស្រុកមានការភ័យខ្លាច។ ការចាប់សត្វខ្លានេះ ជាទូទៅនៅក្នុងភូមិគឺមានអ្នកចេះមន្តអាគម និងចេះក្បួនដាក់អន្ទាក់ ឬអង្គប់ខ្លា។ ក្រៅពីនេះ ពួកគាត់ត្រូវមានការប្រយ័ត្នក្នុងការយកសាច់ខ្លា ឬការរក្សាទុកឆ្អឹងសត្វខ្លាឲ្យមានសុវត្ថិភាព ដើម្បីកុំឲ្យមានការប្រែក្លាយជាព្រាយក្បាលខ្លា។

**ភោះ ជួស យាក់**



ព្រៃអារក្ស អ្នកតា

Spiritual forest

ពាក្យនេះ សំដៅលើព្រៃតំណម ឬព្រៃចុងភូមិ ដែលជនជាតិកួយពីមុនគ្រប់ទីកន្លែងកាលពីសម័យមុនតែងតែកសាងភូមិឋានហើយរក្សាព្រៃមួយកន្លែងធំគួរសមសម្រាប់ជាកន្លែងប្រតិត្តិកម្មវិធីឡើងអ្នកតាប្រចាំឆ្នាំ ឬសម្រាប់បន់ស្រន់ លាបំណន់ និងធ្វើកម្មវិធីសម្បថជាដើម។ ព្រៃដូនតា គឺជាលំនៅសម្ងាត់មួយដែលមិនមានសមាជិកណាមួយទៅប៉ះពាល់បាន ពីព្រោះគេខ្លាចត្រង់ថា អ្នកតានៅព្រៃនោះមើលឃើញពួកគាត់ធ្វើអ្វីៗ តែពួកគាត់មិនអាចមើលឃើញអ្នកតាបានទេ។ ពួកគាត់ត្រូវសម្តែងការគោរពខ្លាំងបើខុសឆ្គងខ្លាំង អ្នកតាអាចយកជីវិត ឬធ្វើឲ្យមានបញ្ហាក្នុងភូមិជាដើម។

## អក្សរ ខ

**ខេល**



ការវាយខែល

Khmer shielding

ពាក្យនេះសំដៅលើសកម្មភាពនៃការវាយខែលដែលជាក្បាច់គុណបង្ហាញពីសមត្ថភាព និងទេពកោសលក្នុងការសម្តែង និងភាពអត់ធ្មត់។ ក្បាច់គុណនេះជាកម្មវិធីប្រពៃណីមួយដែលជនជាតិកួយសម្តែងក្នុងកម្មវិធីចែកឆ្នាំចាស់ចូលឆ្នាំថ្មី។ ក្បាច់គុណនេះ ពីដើមឡើយបង្កប់ទៅ

ដោយវេទមន្ត និងភាពស័ក្តិសិទ្ធិនៃឱសថបូរាណ ដែលការពារស្បែកមិនឲ្យឈឺក្នុងការសម្តែង។ នៅតំបន់ខ្លះគេសម្តែងបង្ហាញអំពីរិទ្ធិនៃការប្រើប្រាស់ថ្នាំស្លឹក ការប្រើផ្គាលបូរាណ ឬការបង្ហាញពីសិល្បៈនៃក្បាច់គុណ ដែលគេសម្តែងសាទរក្នុងពេលដង្ហែរផ្ការប្រាក់ចូលវត្តអារ៉ាមក្នុងកម្មវិធីបុណ្យប្រពៃណី។

## អក្សរ គ

| | | | |
|---|---|---|---|
| **គ្វាល ត្រៀក/ត្រ្វ៉ក**<br> | ឃ្វៀលក្របី ឬ ឃ្វាលគោ | Tend cattle | ពាក្យនេះសំដៅលើសកម្មភាពដែលជនជាតិកួយ កាលពីបុរាណមកដល់បច្ចុប្បន្នតែងតែមានគោច្រើន ឬក្របីទាំងហ្វូង ហើយពួកគាត់បានមើលថែរក្សាដោយដេញឲ្យទៅស៊ីស្មៅនៅវាល ឬព្រៃរបោះ ដែលជាទីតាំងរួមសម្រាប់កន្លែងចិញ្ចឹមគោ ឬក្របី។ ពួកគាត់តែងតែឃ្វាលនៅទីនោះជាប្រចាំ។ ជាទូទៅជនជាតិកួយតែងតែរក្សាទុកព្រៃរបោះ ឬវាលយ៉ាងធំ ដែលមានត្រពាំង អូរ និងបឹងសម្រាប់ទីកន្លែងឃ្វាល និងកន្លែងមើលថែគោ ឬក្របី។ |
| **គ័ស ទ្រខ**<br> | គោះអង្រ្កង ចាក់អង្រ្កង | Collect sour red ant by cracking its nest and put them in a container | ពាក្យនេះ ត្រូវបានជនជាតិកួយប្រើប្រាស់ក្នុងសកម្មភាព នៅពេលដែលពួកគាត់ទៅចាក់អង្រ្កង ឬគាស់អង្រ្កងដើម្បីយកទៅធ្វើម្ហូបអាហារ។ ភាគច្រើនគឺស្ត្រីទៅជាក្រុមដោយប្រើប្រាស់ឧបករណ៍ធ្វើដោយដៃ ដូចជាកន្ត្រក ជាល កញ្ជើ ឬល្អី។ ពេលចាក់អង្រ្កងបាន ពួកគាត់គាស់អង្រ្កងទៅក្នុងថាំង ឬធុងដែលមានទឹក។ នៅពេលបានអង្រ្កងច្រើនពួកគាត់ចែកគ្នាដើម្បីធ្វើអាហារបរិភោគ។ |

| | | | |
|---|---|---|---|
| **គ័ស ក្ចត**  | គោះកង្កែប ឬ ចាក់កង្កែបក្នុងរហែងដីប្រេះ | Find frogs in cracked soil | ពាក្យនេះ ជនជាតិកួយប្រើប្រាស់ក្នុងពេលដែលពួកគាត់បបួលគ្នីគ្នាទៅគាស់ដីនៅតាមត្រពាំងដែលប្រេះរហែង បន្ទាប់ពីរីងទឹកអស់។ នៅពេលស្ថានភាពដីស្ងួតមានប្រហោង ឬប្រេះរហែង ដែលមានកង្កែបរស់នៅក្នុងនោះ ពួកគាត់ជួយគ្នាគាស់ដី រួចហើយពួកគាត់ចាប់យកកង្កែបកូប ឬកង្កែបស្រូវបានយ៉ាងស្រួលដើម្បីយកទៅធ្វើម្ហូបអាហារតាមគ្រួសារ ឬចែកចាយផ្ទះជិតខាង។ សកម្មភាពនេះជាសកម្មភាពប្រពៃណីក្នុងការច្នៃប្រឌិតរកឃើញនូវវិធីថ្មី។ |

## អក្សរ ឃ

| | | | |
|---|---|---|---|
| **ឃៀល គោះ**  | ឃ្មុំមានម្ចាស់ ឬ ឃ្មុំព្រៃមានម្ចាស់ | Domestic bees or managed wild bees | ពាក្យនេះ សំដៅលើសត្វឃ្មុំដែលមានលក្ខណៈកាច សាហាវ មិនអាចនរណាទៅក្បែរបាន។ វាជាឃ្មុំដែលជនជាតិកួយឲ្យជំនឿថាជាឃ្មុំលោកតា។ ឃ្មុំនេះបើមាននរណាធ្វើមិនល្អ ឬមានគំនិតមិនល្អ នៅពេលនោះឃ្មុំនឹងទិចក្នុងពេលដែលពួកគាត់ចូលព្រៃ ហើយបើខុសតំណមនោះឃ្មុំនឹងទិចខ្លាំង។ បើមាននរណាយកឃ្មុំ នៅពេលដែលឃ្មុំនោះដេញនឹង ហើយឃ្មុំនោះដេញរហូតដល់ផ្ទះ ហើយមានអ្នកខ្លះរត់ចូលមុងដើម្បីសុវត្ថិភាពក៏មានដែរ។ |

## អក្សរ ខ

| | | | |
|---|---|---|---|
| **ខារ អែំល**  | ជម្ងឺកាចសាហាវឬជម្ងឺងារបាល | Malignant disease | ពាក្យនេះ ជនជាតិកួយប្រើសំដៅលើស្ថានភាពនៃជម្ងឺដ៏កាចសាហាវ ឬក្នុងស្ថានភាពដ៏អាក្រក់លើសុខភាពសត្វ។ នៅពេលដែលសត្វពាហនៈ ឬសត្វបក្សីក្នុងស្រុកបានស្លាប់រង្គាលនៅតាមផ្ទះ អ្នកស្រុកជនជាតិកួយហៅជម្ងឺនេះថា ងារវាយក។ ដូច្នេះដើម្បីការពារជម្ងឺទាំងនេះមិនឲ្យកើត |

ឡើង អ្នកស្រុកមានជំនឿថាត្រូវតែសែនជូនដូនតា លាងគ្រោះចង្រៃដែលធ្វើក្នុងពេលពិធីឡើងអ្នកតា។

## អក្សរ ច

| | | | |
|---|---|---|---|
| **ចាំ ព្លី ប៉ាញ់ ចែម** *(តំបន់ស្រើ)* **ចាំ ប្លី ប៉ាញ់ ចែម** *(តំបន់ស្វ៊ា)*  | ចាំបាញ់សត្វមកស៊ីផ្លែឈើ | Wait for shooting animals or birds to come and eat fruit | ពាក្យនេះសំដៅលើ សកម្មភាពដែលជនជាតិកួយ ជាពិសេសបុរសៗ ដែលជាក្រុមព្រានព្រៃកាលពីបុរាណ (វចនានុក្រមសម្ដេចសង្ឃជួនណាតហៅថាព្រានសត្វ (គ្រាមភាសាកួយ) ដែលចេះដឹងខាងរបៀបបរបាញ់សត្វតាមប្រពៃណីដើម្បីបានសត្វ (ឈ្លូស ប្រើស រមាំង ខ្ទីង ខ្លា ជាដើម)។ គោលបំណងដើម្បីយកទៅធ្វើជាអាហារ និងចែកចាយបងប្អូនក្នុងភូមិ ដើម្បីបានបរិភោគទាំងអស់គ្នា។ នៅពេលបានសត្វ គឺព្រានសត្វផ្លុំស្នែង ឬផ្លុំអង្គប់ដើម្បីហៅកម្លាំងអ្នកស្រុកទៅយកសាច់ទុកហូបតាមផ្ទះ។ |
| **ចោះ ឆ្កាខ**  | យកម្រូម ឬចោះម្រូម | Take Marom (stingless bees) by piercing | ពាក្យនេះសំដៅលើសកម្មភាពដែលជនជាតិកួយ ជាប្រពៃណីគឺពួកគាត់មានគ្នាជាក្រុម ដោយបុរសៗនាំគ្នាទៅព្រៃឆ្ងាយពីភូមិ ដើម្បីទៅចោះម្រោមដែលមាននៅតាមរន្ធដើមឈើ។ ពួកគាត់ប្រើប្រាស់ចំណេះដឹង និងបច្ចេកទេសដើម្បីបានម្រោម ហើយយកទៅចម្រាញ់ យកក្បាលទឹកទៅធ្វើជាឧសថ ឬបរិភាគជាមួយអាហារផ្សេងៗតាមរបៀបរបស់ជនជាតិកួយពីបុរាណ។ |
| **ចេក ថ៉ារ់ តី** | ថ្នាំវល្លិ៍គុយ | Kui (vine) medicine | ពាក្យនេះសំដៅលើប្រភេទដើមឈើជាវល្លិ៍គុយ ដែលជាទូទៅជនជាតិកួយតែងតែឲ្យតម្លៃក្នុងការថែរក្សា ការការពារ និងការប្រើប្រាស់វល្លិ៍ |

| | | | |
|---|---|---|---|
|  | | | គុយនេះសម្រាប់ព្យាបាលជម្ងឺដែលពាក់ព័ន្ធទៅនឹងស្ថានភាពសុខភាពរបស់ស្ត្រី ដែលភាសាសាមញ្ញជនជាតិកួយហោះថា (ថ្នាំទាស់ទឹកដោះនៅពេលស្ត្រីកូនខ្ចី)។ ក្រៅពីនេះ គេអាចយកដើមវាស្ងោរទឹកផឹក ឬត្រាំជាមួយស្រាសរជំនួយសសៃរឲ្យដើរស្រួល ហើយគេក៏អាចហូបផ្លែវាដែលមានរស់ជាតិជូរអែមទៀតផង។ |
| **អក្សរ ឆ** | | | |
| **ឆ្អែខ ម៉ែ**  | ជាពាក្យជេរប្រមាថ | An insult | ពាក្យនេះសំដៅលើការជេរទៅលើនរណាម្នាក់ ដែលបានធ្វើឲ្យនរណាមួយខឹងសម្បា ហើយប្រតិកម្មទៅវិញដោយមុខខឹងហើយប្រើពាក្យនេះជាការជេរ ឬបណ្តាសារ ដោយប្រៀបធៀបទៅនឹងស្ថានភាពអ្នកស្លាប់ដែលហើមប៉ោង ហៀរខ្លាញ់ដូចគេយកទៅដុតចោល។ ពាក្យនេះ មានប្រើប្រាស់ដោយជនជាតិកួយនៅតាមតំបន់ខ្លះ មិនទូទៅទេ។ |
| ហ្បែង ឡែត | ពាក្យនេះប្រើសំដៅលើទង្វើមិនពេញចិត្ត | Refer to bad commitment of someone. | ពាក្យនេះចាស់ៗកួយ ប្រើភាគច្រើនសំដៅលើទង្វើរបស់នរណាម្នាក់ដែលនិយាយស្តីមិនគប្បី និងមិនមានប្រយោជន៍ ដូច្នេះអ្នកស្តាប់ហាក់ដូចជាមិនពេញចិត្តហើយក៏ប្រើពាក្យនេះតែម្តង។ |
| **អក្សរ ជ** | | | |
| **ជា ម៉ិច ផ្ទាល** | ជីកប្រទាល | Dig succulent plants | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (ទាំងបុរស ទាំងស្ត្រី) ជីកយកផ្ទាលពីក្នុងព្រៃក្បែរភូមិ ឬឆ្ងាយពីភូមិដែលដុះក្នុងព្រៃធំ។ ការជីកនេះ គេត្រូវទៅគ្នាច្រើននាក់ ដើម្បីការពារសុវត្ថិភាពពីសត្វ (ជ្រូកព្រៃ ខ្លាដំរី...) ពីព្រោះជ្រូកក៏ឈ្មុលជីស៊ីផ្ទាលនេះដែរ ហើយសត្វខ្លាគឺរកស៊ីជ្រូក |

| | | | |
|---|---|---|---|
|  | | | ព្រៃ។ ពួកគាត់ជីកផ្កាលនេះ គោលបំណងដើម្បីយកទៅបំពុលត្រីនៅតាមអូ ឬបឹងឲ្យពុលដើម្បីងាយស្រួលចាប់យកទៅធ្វើជាអាហារ។ |
| **ជួក ញ៉្វក**<br>*(តំបន់ក្រើ)*<br>**តាប់ ញ្វក់**<br>*(តំបន់អ្វ័)*<br> | បុកម្ជូហូប | Make mixed sour fruit (Maju) with spicy dipping sauce | ពាក្យនេះ សំដៅលើសកម្មភាពរបស់ក្រុមស្ត្រី ឬក្រុមយុវជន ឬយុវនារីដែលឯកភាពគ្នាទៅរកផ្លែឈើជូរ ឬផ្លែណាមួយដែលហូបបាន ហើយរួមគ្នាបុកម្ជូរ រួចហូបជុំគ្នា ដោយបង្ហាញពីការសាមគ្គីគ្នា ក្នុងនោះអ្នកដឹកនាំការបុកម្ជូរគេដាក់ចំនួនផ្លែម្ទេសទៅតាមអាយុរបស់អ្នកបុកម្ជូរ។ នៅពេលហូបគេភ្នាល់គ្នាអំពីការឈ្នះក្នុងការហូប តើនរណាអាចទ្រាំនឹងការហិរបាន។ |
| **ជៀ រិត ភា**<br> | ការទៅរុតត្រី | Fishing with Angrot (Khmer fishing gear) | ជាពាក្យដែលជនជាតិកួយប្រើប្រាស់ក្នុងសកម្មភាពរុតត្រីនៅតាមត្រពាំង បឹងតូច អូរ ឬប្រឡាយ។ ការរុតត្រីធ្វើឡើងក្រោយពីពួកគាត់បានជួបជុំនិងឯកភាពគ្នានៅក្នុងភូមិ ហើយពួកគាត់មានសភារៈសម្រាប់រុតទៅជាមួយផង និងមានវេចបាយ ឬដាក់អង្ករទៅដាំបាយ។ ក្នុងការរុតត្រីគឺតែងតែមានការបួងសួង ឬពោលពាក្យសុំម្ចាស់ព្រៃ ឬម្ចាស់ទឹកដើម្បីឲ្យបានត្រី និងសុំសេចក្តីសុខផងដែរ ដោយសារតែកន្លែងរុតត្រីជាទីតាំងដែលពួកគាត់មានជំនឿថាមានម្ចាស់ថៃទើបមានត្រីរស់នៅកកកុញ និងមាទឹកខ្ជួបប្រាំងផងដែរ។ |

| | | | |
|---|---|---|---|
| **ជី ស្រែំ ជីស្រ៉ែ**<br>*(តំបន់អ្រ្វី)*<br>**ជៀស្រែំ ជៀស្រ៉ែ**<br>*(តំបន់អ្វ័)*<br> | ទៅស្រែចម្ការ | Go to the farm or plantation | ពាក្យនេះ សំដៅលើសកម្មភាពជាប្រពៃណីដែលជនជាតិកួយ ទៅស្រែ ឬទៅចម្ការជាក្រុម ឬជាគ្រួសារសាច់ញាតិ។ ពួកគាត់មានស្រែ ចម្ការធំៗទៅតាមស្ថានភាពកម្លាំងអាចធ្វើបាន ដោយមានដីប្រើប្រាស់ដាំដំណាំស្រូវស្រែ ដីត្រៀមចម្ការវិលជុំ ដីទុកចញ្ចឹមសត្វនៅរដូវវស្សា និងដីត្រៀមចែកកូនៗ។ ក្នុងពេលវគ្គបង្កបង្កើនផល ការថែទាំ និងការប្រមូលផល ពួកគាត់ដេកនៅទីនោះជាក្រុមស្រែតំបន់ជាមួយគ្នា រហូតដល់ពេលដឹកទិន្នផលស្រូវទៅដាក់ជង្រុកនៅផ្ទះ។ |
| **ជូក កាស៊ីម**<br>*(តំបន់អ្រ្វី)*<br>**អ្វាត់ កា សោម**<br>*(តំបន់អ្វ័)*<br> | ចូកកំពឹស | Shrimping (by using nets, traps, even handpicking) | ពាក្យនេះ សំដៅលើសកម្មភាពជនជាតិកួយ (ស្ត្រី) ជាប្រពៃណីទៅរកត្រីតាមអូរ ប្រឡាយ និតត្រពាំងដែលមានទឹក និងមានត្រីរស់នៅ។ ពួកគាត់មានគ្នាជាក្រុម និងមានឈ្នាង ដើម្បីចូកកំពឹសផង និងរកត្រីផង។ ត្រី ឬកំពឹសដែលរកបានពីការចូកនេះ គឺមានរស់ជាតិឆ្ងាញ់។ |
| **ជៀ កោប ក្ឃួត**<br>*(តំបន់អ្រ្វី)*<br>**ជៀ កប ក្ឃួត**<br>*(តំបន់អ្វ័)* | ចាប់កង្កែប | Catch frogs | ពាក្យនេះសំដៅលើសកម្មភាព ដែលជនជាតិកួយទាំងប្រុសទាំងស្រីទាំងក្មេងទាំងចាស់ ប្រើប្រាស់វានៅក្នុងសកម្មភាពដែលពួកគាត់នាំគ្នាទៅចាប់កង្កែប (កង្កែបហ៊ឹង កង្កែបត្រូក កង្កែបជ័រ និងកង្កែបកូបជាដើម)។ ក្រោយពីមានភ្លៀងធ្លាក់មួយមេ ឬពីរមេរយ៉ាងច្រើន ហើយមានទឹកនៅតាមថ្លុក ឬតាមត្រពាំង តាមប្រឡាយ តាមអូរនៅដើមឆ្នាំ។ អ្នក |

រក្សាសិទ្ធិរបស់ OPKC



ស្រុកបានបបួលគ្នាក្នុងភូមិទៅរកចាប់កង្កែបនៅតាមទីតាំងដែលមានសម្លេងកង្កែបពេទ័ទ្រហឹង អ៊ឹងកង។

**ឆ្វាត់ ភា**



ជញ្ជាត់ត្រី

Catch fish in shallow water

ពាក្យនេះ ប្រើនៅពេលដែលស្ត្រីជនជាតិកួយនាំគ្នាទៅជញ្ជាត់ត្រីអូរនៅទីតាំងដែលមានទឹករាក់ ឬទឹកដែលបម្រុងនឹងរីង ហើយនៅសល់ត្រីរស់នៅ ដោយសារតែនៅតាមទីតាំងដែលមានទឹកគឺសម្បូរទៅដោយស្លឹកឈើច្រើន។ ពួកគាត់ទៅដោយមានគ្នាច្រើនដើម្បីសុវត្ថិភាពពីមនុស្ស និងសត្វផ្សេងៗដែលចូលចិត្តរស់នៅតាមអូរដើម្បីចាប់សត្វជាចំណីផងដែរ។

## អក្សរ ឈ

**ឈូសឆ្នោល**
**ឈូសល័ខ**
**ឈូសភាតារ**



ការងារឈូសឈើ ឬ សសេរ ឬក្តា

Wood flattening and inscription

ពាក្យនេះ សំដៅលើសកម្មភាពជនជាតិកួយ (បុរសជាជាងឈើ) ដែលប្រើប្រាស់ចំណេះដឹងក្នុងការងារឈូសសសេរធ្វើផ្ទះ ឈូសឈើធ្វើរទេះ ឬធ្វើដងចប ជ្រនីក ឬឈូសក្តារជាដើម។ ជនជាតិកួយធ្វើដែកឈូសពីឈើ និងដែកហើយធ្វើសកម្មភាពឈូសសម្អាត់វត្ថុទាំងនោះឲ្យស្អាត។

## អក្សរ ញ

**ញាម រាល់ ស្តៅ**

យំរាល់យប់

Cry every night

ពាក្យនេះ សំដៅលើក្មេងយំមិនបានបាត់នៅពេលយប់ ជាទូទៅក្មេងយំយប់ហើយមានលក្ខណៈស្រែកខ្លាំងៗ លួងមិនបាត់យំ ពេលខ្លះយំមិន

បានដេក ដោយមានអាការៈខុសប្លែកៗ។ ជនជាតិកួយមានជំនឿថាក្មេងនោះខុសអ្វីមួយ ដូច្នេះគេត្រូវយកក្មេងនោះទៅស្តោះផ្លុំ ឬទៅបូលប្រណាក ឬបូលពងមាន់ ឬបញ្ចូលមេមត់ ឬបញ្ជាន់អារក្សដើម្បីរកមូលហេតុ។ ក្រោយពីការរកឃើញមូលហេតុ ក្មេងនោះក៏ឈប់យំ ហើយមានសភាពធម្មតាវិញ។

## អក្សរ ដ

| | | | |
|---|---|---|---|
| **ដាក់ ឡាយ**<br> | ដាក់លាយ/ទ្រូ | Fishing with Leay/Trou (Khmer bamboo fishing gear) | ជាពាក្យ ដែលជនជាតិកួយបានប្រើប្រាស់ចំណេះដឹងក្នុងការរៀបចំទីតាំងសម្រាប់ដាក់លាយ ឬដាក់ទ្រូដើម្បីបានត្រី។ វាជាវិធីបូរាណមួយដើម្បីបានត្រីយកទៅធ្វើម្ហូបអាហារ។ ទីតាំងដាក់គឺស្ថិតនៅតាមអូរ ឬប្រឡាយដែលសំបូរទៅដោយត្រីឡើង ឬត្រីចុះ។ សកម្មភាពនេះ គឺធ្វើនៅរដូវវស្សា និងរដូវរំហើយ នៅពេលដែលទឹកអូរស្រកទឹក។ |
| **ដាក់ អ្នាក់**<br> | ដាក់អន្ទាក់ | To trap | សំដៅដល់ សកម្មភាពដែលជនជាតិកួយដែលជាព្រានព្រៃយកសំភារៈ និងឧបករណ៍ទៅធ្វើអន្ទាក់យកសត្វព្រៃដូចជាសត្វជ្រូកព្រៃ ប្រើសរមាំង ក្តាន់ ខ្ទីងជាដើម។ល។ ដោយប្រើវិធីឧបកិច្ចស្លឹក និងកូកព្រៃដើម្បីសុំសត្វកំបាក់កំបែកយកទៅធ្វើជាអាហារ និងចែកអ្នកស្រុកបានហូបដូចគ្នា។ |
| **ដុខ ឆៀ** | ផ្ទះចាស់ | Old fashion house | ពាក្យនេះ សំដៅលើផ្ទះចាស់ នៅតំបន់ខ្លះ ជនជាតិកួយនៅពេលមានគូរស្រករតឺពួកគាត់ចាប់ផ្តើមសាងសង់ផ្ទះមួយខ្នងតូចសម្រាប់ជាទីជម្រកក្នុងគ្រួសារ ហើយបន្ទាប់មកគ្រួសារនោះមានកូនច្រើនឡើងៗ |



(កាលពីដើមគ្រួសារនិមួយៗមានកូនយ៉ាងតិច៥នាក់) និងបានចាប់ផ្តើមអារឈើគ្រឿងផ្ទះដោយមានអ្នកស្រុកជួយផងដែរ។

**ដុខ ត្មាយ**
*(តំបន់អ្រើ)*
**ដុខ ត្មៃ**
*(តំបន់អ្វ័)*



ផ្ទះថ្មី ឬផ្ទះម៉ូតថ្មី

New fashion house

ពាក្យនេះ សំដៅលើផ្ទះដែលសាងសង់ថ្មី ឬម៉ូតថ្មីសម្រាប់គ្រួសារដែលធូធារហើយ ជាទូទៅ ពីដើមជនជាតិកួយ នៅពេលសាងផ្ទះគឺពួកគាត់ចេះជួយគ្នាទៅវិញទៅមក ដោយជួយទ្រង់ទ្រាយធំគឺការផ្តុំផ្ទះចំណាយពេលមួយថ្ងៃ និងលើកផ្ទះចំណាយពេលមួយថ្ងៃ ពេលល្ងាចពួកគាត់ចាប់ផ្តើមសែនព្រេនយកថ្ងៃឡើងនៅលើផ្ទះផ្ទះ ដោយមានពិធីសាសនា និងកម្មវិធីកំសាន្ត។

**ដុខ យាក់ ជួស**



ខ្ទមអ្នកតា

Spirit houses

ពាក្យនេះ សំដៅលើទីតាំងដែលមានខ្ទមប្រក់ស្បូវ ឬស្លឹកហើយមានរូបសំណាកអ្នកតា ជាមួយសំភារៈជាគ្រឿងការពាររបស់អ្នកតាចាស់ស្រុក។ ខ្ទមអ្នកតាជាទីតាំងសក្ការៈរបស់ជនជាតិកួយ

រក្សាសិទ្ធិដោយ OPKC

## អក្សរ ត

**តាប់ ញូក់**



បុកម្ហូបហូប

Eat pickles

ពាក្យនេះ សំដៅលើសកម្មភាពរបស់ក្រុមស្ត្រី ឬយុវជនដែលឯកភាពគ្នាទៅរកផ្លែជូរ ឬផ្លែណាមួយដែលហូបបាន ហើយរួមគ្នាបុកម្ជូរ រួចហូបជុំគ្នា បង្ហាញពីការសាមគ្គីគ្នា ក្នុងនោះអ្នកដឹកនាំការបុកម្ជូរគេដាក់ចំនួន

| | | | |
|---|---|---|---|
| | | | ផ្លែម្ទេសទៅតាមអាយុរបស់អ្នកបុកម្ទេរ។ នៅពេលហូបគេភ្នាល់គ្នាអំពីការឈ្នះក្នុងការហូប។ |
| ក្នុច អែល ភា  | អង្គុយចាំចាប់ ឬកាប់ត្រីតាមអូរ | Catching and cutting fish in stream | ពាក្យនេះ សំដៅវិធីមួយ ដែលជនជាតិកួយពីបូរាណតែងតែនាំគ្នីគ្នាទៅអងចាប់ត្រី ឬកាប់ត្រី ឬជួសត្រីតាមអូរ ឬប្រឡាយ ដោយពួកគាត់រៀបចំជាសម្រះ និងបិតមុខទឹករួចទុកមុខទឹកឲ្យត្រីរត់ចុះរត់ឡើង។ |
| តាប់ ព័ស ល្ងឹខ  | បុកអំបិលល្ង | Make sesame salt | ពាក្យនេះ ភាគច្រើនស្ត្រីសំដៅលើជនជាតិកួយ (ស្ត្រី) តែងតែបុកអំបិលល្ង ដើម្បីបរិភោគក្នុងគ្រួសារ និងរក្សាទុកបានយូរ ដែលពួកគាត់អាចវេចខ្ចប់ទៅព្រៃសម្រាប់បរិភោគជាមួយនិងបន្លែព្រៃនៅពេលពួកគាត់សម្រាកព្រៃ ដោយមានភាពងាយស្រួលហូបអាហារតាមព្រៃ ឬទៅចម្ការ ឬតាមស្រែ។ |
| តាក់ ត្រៀ  | បេះឬបោចផ្សិត | Pick up mushroom | ពាក្យនេះ ជនជាតិកួយប្រើប្រាស់ជាទូទៅក្នុងសកម្មភាពប្រមូលគ្នីគ្នាទៅបេះផ្សិត ឬទៅរកផ្សិត។ ជាទូទៅគាត់ទៅរកផ្សិតជាក្រុម ដោយមមានឧបករណ៍ប្រើប្រាស់បែបប្រពៃណី។ ពេលខ្លះពួកគាត់វេចខ្ចប់នឹងស្លឹកខ្លង ឬស្លឹកត្បែង ឬជាល ឬកញ្ជើរដែលយកទៅពីផ្ទះ។ នៅពេលបានផ្សិតពួកគាត់អាចលក់ និងទុកហូបក្នុងគ្រួសារ និងអាចចែកចាយទៅដល់សាច់ញាតិក្នុងភូមិផងដែរ។ |

រក្សាសិទ្ធិដោយ OPKC

| | | | |
|---|---|---|---|
| **តាក់ ព្លី គី**<br>*(តំបន់ក្រើ)*<br>**តាក់ ប្លឹ គី**<br>*(តំបន់អ្វ៊ែ)*<br> | បេះផ្លែគុយ | Pick up Kui (Khmer wild fruit) | ពាក្យនេះ ជនជាតិកួយប្រើប្រាស់ក្នុងរដូវខែពិសាយដែលនៅតាមព្រៃឆ្ងាយពីភូមិ ពួកគាត់បបួលគ្នីគ្នាទៅរកផ្លែគុយដោយប្រើសមត្ថភាពក្នុងការឡើងបេះផ្លែគុយបាន។ ជាទូទៅជនជាតិកួយបេះផ្លែគុយយកទៅបរិភោគជាផ្លែឈើផ្អែមទូទាំងភូមិ ឬជាក្រុមដែលពួកគាត់មានជំនឿរថាជាផ្លែឈើឧសថ ។ ក្រៅពីនេះពួកគាត់អាចលក់បានជាប្រាក់ចំណូលដើម្បីទិញគ្រឿងទេសសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ |
| **តាក់ ព្លី ឡូខ**<br>*(តំបន់ក្រើ)*<br>**តាក់ ប្លឹ លំខ**<br>*(តំបន់អ្វ៊ែ)*<br> | បេះផ្លែព្រីង | Pick up jambolan plum (Pring | ជនជាតិកួយ តែងតែបបួលគ្នីគ្នាទៅបេះផ្លែព្រីងដែលមាននៅតាមវាលស្រែ ឬព្រៃរបោះ ឬព្រៃស្រោង ពួកគាត់ទៅជាក្រុម មានបុរសៗជាអ្នកឡើងដើមអង្រួនផ្លែឲ្យជ្រុះ ដើម្បីអ្នកផ្សេងទៀតជាអ្នកចាំរើសនៅខាងក្រោមដើម ពួកគាត់រើសផ្លែព្រីង ហើយយកទៅហូបនៅភូមិ និងចែកចាយដល់អ្នកផ្សេងៗទៀតនៅក្នុងភូមិដើម្បីហូបកំសាន្ត និងហូបផងពិភាក្សាគ្នាផងដែរ។ |
| **តំបូរ ភា**<br> | វេចត្រីខ្នប់ | Make fish dish (Khnab) | សំដៅលើម្ហូបមួយបែបមានរស់ជាតិឆ្ងាញ់ ដែលជនជាតិកួយទាំងបុរសទាំងស្ត្រី តែងតែយកត្រីចង្វារពីអូ ប្រឡាយ ឬត្រពាំងមកលាយផ្សំជាមួយគ្រឿងទេសផ្សេងៗ ដោយវេចខ្ចប់ជាមួយស្លឹកឈើពីព្រៃដែលមានទ្រង់ទ្រាយធំ (ខ្លង មមាំង ត្រសើម អាឡោក រលាយ ត្បែង....) យកទៅអាំងនឹងភ្លើង បន្ទាប់យកទៅហូបជុំគ្នា ឬចែកគ្នាហូប។ |

| | | | |
|---|---|---|---|
| **ត្យះ ក្មួត**<br> | បបក់កង្កែប | Fish frogs with rods | ពាក្យនេះ ជនជាតិកួយជាបុរស ឬយុវជនតែងប្រើប្រាស់ជាក្រុមនៅក្នុងការទៅបបក់កង្កែបនៅតាមត្រពាំង ឬស្រះក្នុងព្រៃ ដោយប្រើប្រាស់ដៃឬស្សី ឬកូនឈើជាដង ដាក់នុយជាស្បែកកង្កែបរួចបោះចូលក្នុងទឹកត្រពាំងដោយសញ្ញាផ្សេងៗឲ្យកង្កែបដេញលេប។ នៅពេលដែលកង្កែបលេបចូលហើយគេវាត់ឈើ ឬឬស្សីទៅក្រោយដោយជាមួយនឹងកង្កែប។ ការបបកជាវិធីសាស្រ្តមួយដែលជនជាតិកួយប្រើប្រាស់ដើម្បីឲ្យបានកង្កែបកូបច្រើនយកទៅជាអាហារ។ |
| **តាក់ ឡា ប្រិច**<br> | បេះស្លឹកប្រិច | Forage for edible leaves (Prich) | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (ប្រុស ស្រី) នាំគ្នាទាំងហ្វូងទៅរក និងបេះស្លឹកប្រិចនៅតាមព្រៃដែលនៅឆ្ងាយពីភូមិប្រមាណ១០គីឡូ អាស្រ័យទៅតាមស្ថានភាពភូមិនៅតាមតំបន់។ ដើមប្រិចមានដុះតាមតំបន់ព្រៃ ឬស្ថានភាពដីដែលមានទីទួល និងមានដំបូក។ អ្នកបេះស្លឹកប្រិចត្រូវមានទឹក បាយ និងម្ហូបទៅជាមួយ ឬក៏មានសត្វឆ្កែទៅអមដើម្បីការពារសុវត្ថិភាពតាមដងព្រៃ។ គេអាចយកប្រិចធ្វើជាអាហារ ចែកគ្នាហូប និងលក់បានជាថវិកាផ្គត់ផ្គង់ជីវភាពផងដែរ។ |
| **តាក់ ឡា អក ខ្ទក់**<br> | បេះស្លឹកអកខ្ទក់ | Forage for edible leaves (Orkhatuk) | ពាក្យនេះសំដៅលើ សកម្មភាពដែលជនជាតិកួយក្នុងសហគមន៍ទៅបេះត្រួយអកខ្ទកយកទៅធ្វើជាបន្លែ ឬស្លម្ហូបដែលមានរស់ជាតិឆ្ងាញបែបធម្មជាតិ ហើយជាបន្លែឧសថផងដែរ។ អ្នកបេះស្លឹកអកខ្ទក់អាចទៅបេះគ្នា២នាក់ ឬគ្នាជាក្រុម ដោយពួកគាត់អាចបេះបានគ្រប់រដូវ ជាពិសេសរដូវស្លឹកឈើលាស់ ក្រោយពីភ្លើងខេះរោល។ |

| | | | |
|---|---|---|---|
| **តាក់ ឡា ច្រីស**<br> | បេះស្លឹកច្រេស | Forage for edible leaves (Jres) | ពាក្យនេះសំដៅលើ សកម្មភាពដែលជនជាតិកួយក្នុងសហគមន៍ទៅបេះស្លឹកច្រេសទើបលាស់ខ្ចី យកទៅធ្វើជាបន្លែ ឬស្លកកូរ ឬស្លប្រហើរបានដែលមានរស់ជាតិឆ្ងាញ់បែបធម្មជាតិ ហើយជាបន្លែឧសថផងដែរ។ អ្នកបេះស្លឹកច្រេសអាចទៅបេះគ្នា២នាក់ ឬគ្នាជាក្រុម ដោយពួកគាត់អាចបេះបានគ្រប់រដូវ ជាពិសេសរដូវស្លឹកឈើលាស់ ក្រោយពីភ្លើងឆេះរោល។ |
| **តាក់ ឡា ចឹង**<br> | បេះស្លឹករាំង | Forage for edible leaves (Raing) | ពាក្យនេះ សំដៅលើសកម្មភាពការបេះស្លឹករាំង ដែលជនជាតិកួយ (ស្ត្រី) នាំគ្នាទៅបេះដែលមានដុះនៅតាមមាត់អូរ ឬមាត់ប្រឡាយ។ ពួកគាត់បេះអមក្នុងសកម្មភាពដងទឹក ឬទៅរកអុសជាដើម។ |
| **តាក់ ឡា ទ្មូង**<br> | បេះស្លឹកម្ទូត្រមូង | Forage for edible sour leaves (Tramoung) | ពាក្យនេះសំដៅលើសកម្មភាព ដែលជនជាតិកួយប្រើប្រាស់នៅពេលដែលពួកគាត់ទៅបេះស្លឹកទ្រមូង ដើម្បីយកទៅស្លម្ជូរគ្រឿង នៅពេលដែលពួកគាត់បានសាច់ពីព្រៃ ហើយពួកគាត់ជួបជុំគ្នាហូបរួមគ្នា មានកម្មវិធីសប្បាយបង្កើនសាមគ្គីភាព។ |

| | | | |
|---|---|---|---|
| **តាក់ ឡា ស្អេញ**<br> | បេះស្លឹកម្ជូរធ្នឹង | Forage for edible sour leaves (Thnoeng) | ពាក្យនេះ សំដៅលើសកម្មភាពស្ត្រីជនជាតិកួយទៅបេះស្លឹកធ្នឹងដើម្បីធ្វើជាម្ជូរសម្រាប់ស្លហូបនៅពេលពួកគាត់បានសាច់ពីព្រៃ។ |
| **តាក់ ត្រៀ ខោក**<br> | បេះផ្សិតក្លោក | Pick up Kangork mushroom | ពាក្យនេះសំដៅលើសកម្មភាពដែលជនជាតិកួយ (ស្ត្រី) នាំគ្នាទៅបេះផ្សិតក្លោកដែលមានដុះនៅតាមវាលដែលមានព្រៃ និងនៅមាត់ព្រៃ។ ផ្សិតនេះបានធ្វើឲ្យជនជាតិកួយសប្បាយចិត្ត និងបង្កើនសាមគ្គីភាពដែលអាចធ្វើឲ្យពួកគាត់យកបន្លែទៅធ្វើម្ហូប និងអាចលក់បានប្រាក់ចំណូល។ |
| **ភ្លួម ចែក**<br> | ដើមថ្នាំ | Medicinal plants | ពាក្យនេះសំដៅលើប្រភេទដើមឈើដែលជនជាតិកួយកំណត់សំគាល់ថាជាប្រភេទដើមឈើឱសថបូរាណ ដែលជនជាតិកួយតែងតែមានជំនឿលើដើមឈើដែលមានភាពស័ក្តសិទ្ធក្នុងការព្យាបាលជម្ងឺផ្សេងៗ។ |
| **តើល ភ្លួខ តាក** | ទួលអាចម៍ដែក | Arch Dek hill | ពាក្យនេះ សំដៅដល់ទីតាំង ឬដីព្រៃដែលមានស្លានីយស្លដែកពីបូរាណដែលជនជាតិកួយពីបូរាណបានយកទីតាំងទួល ឬដីខ្ពស់ដើម្បីបង្កើតកន្លែស្លដែក ឬសន្លូងស្លដែក។ ជនជាតិកួយដែលមានចំណេះដឹងខាងស្ល |

| | | | |
|---|---|---|---|
|  | | | ដែកបានអនុវត្តជំនាញ និងចំណេះដឹងមន្តអាគមដើម្បីផលិតដែកពិសេសនេះបានសម្រាប់ប្រើប្រាស់។ |
| **ត្រប៉ាំង អែល ភា**  | ត្រពាំងចាប់ត្រី | Natural pong for fishing | ជនជាតិកួយ កំណត់ និងរក្សាត្រពាំងដែលមានត្រីច្រើនទុក ដល់ពេលទឹករីងអស់ នៅទឹកតិចពេលនោះពួកគាត់ចុះបាចទឹកចេញរួចចាប់ត្រីក្នុងត្រពាំងតែម្តង។ |
| **ត្វម អ្នម**  | វិចអន្សម | Make Nom Ansom (sticky rice cake) | សំដៅដល់សកម្មភាពនៃការវេចអក្សម ដែលជនជាតិកួយវេចអក្សមជ្រូក អក្សរក្បុង អន្សមចេក អក្សមគម ឬអក្សមត្នោតនៅក្នុងកម្មវិធីបុណ្យភូមិ កម្មវិធីឡើងអ្នកតា កម្មវិធីអាពាហ៍ពិពាហ៍ ឬកម្មវិធីសេនព្រេនជាដើម។ |
| **តាក់ ញ៉ូក សណ្ដារ**  | បេះម្ជូរសណ្ដាន់ | Pick up Sandan (for sour soup) | ពាក្យនេះសំដៅលើជនជាតិកួយតែងតែបេះផ្លែសណ្ដាន់នៅពេលពួកគេមានកម្មវិធីប្រពៃណី។ |

## អក្សរ ប

OPKC

| | | | |
|---|---|---|---|
| **ប៉ុម ប៉ក គ្រាស**  | បំពក់កង្ហែន | Use smoke to catch Kanghen (striped squirrel) | ពាក្យនេះ សំដៅលើសកម្មភាពដែលបុរសជាជនជាតិកួយជាប្រពៃណី តែងតែនាំគ្នីគ្នាទៅរកកង្ហែនតាមព្រៃ ឬតាមវាល ក្រោយពីភ្លៀងធ្លាក់មួយមេរ ដោយពួកគាត់ប្រើប្រាស់ចំណេះដឹងដើម្បីបានសត្វកង្ហែនយកទៅធ្វើជាអាហារ ហើយពួកគាត់បានចែករំលែកគ្នាបរិភោគតាមផ្ទះផងដែរ។ |
| **ប៊ិច ប្រែ្រល ត្កត** *(តំបន់ស្រ្អី)* **ប៊ិច ប្រៀ្រល ត្កត** *(តំបន់អ្វ័)*  | ជីកពងត្រកួត | Dig for monitor lizard eggs | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (បុរសពេញវ័យ) ប្រើប្រាស់ចំណេះដឹងប្រពៃណីក្នុងការរកសត្វព្រៃ។ បុរសជាជនជាតិកួយដែលមានការយល់ដឹងពីប្រពៃណីសត្វត្រកួត និងការបន្តពូជរបស់សត្វនេះ ហើយជីករកពងត្រកួតដែលមាននៅក្នុងព្រៃដើម្បីយកទៅម្ហូប។ |
| **ប៊ឹរ ចែក**  | រកថ្នាំ ឬរកឱសថបូរាណ | Find traditional medicine | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយប្រើប្រាស់ដូចជា៖ ១/មនុស្សប្រុសរកថ្នាំឈើព្យាបាលរោគក្នុងខ្លួន (នៅពេលដែលត្រូវអំពើគេ) ។ ២/រកថ្នាំឈើព្យាលរោគប្រចាំកាយស្មោធឹក ត្រាំងូត (នៅពេលហើមជើង ហើមដៃ ឬអាការៈផ្សេងៗទៀត)។ ៣/មនុស្សស្រីរកថ្នាំសម្រាប់ព្យាបាលដល់ស្ត្រីដែលមានបញ្ហាសុខភាពតាមផ្លូវរាង្គកាយ ឬសុខភាពស្ត្រី។ |

| | | | |
|---|---|---|---|
| **បុក តូក ក្លូខ**<br> | ដកចាហួយ | Pick up Jahuoy (pink flowers) | ពាក្យនេះ សំដៅដល់សកម្មភាព ដែលជនជាតិកួយ (ប្រុស ស្រី) នៅក្នុងភូមិមួយ បាននាំគ្នីគ្នាចូលព្រៃដកចាហួយដែលជាបន្លែព្រៃ ដែលមានដុះនៅក្នុងតំបន់ព្រៃរបោះ ឬព្រៃស្រោងនៅចន្លោះខែមេសាទៅខែមិថុនា។ ពួកគាត់ទៅរកបន្លែព្រៃជាក្រុម ជាពិសេសស្ត្រីពាក់ព័ន្ធក្នុងសកម្មភាពនេះដើម្បីបានបន្លែយកទៅបរិភោគ ដែលជាបន្លែព្រៃនេះជាបន្លែឱសថ។ |
| **ប៉ាច់ ល្អាខ**<br> | កាប់ឈើភ្លើង | harvest Chhoeu Plerng (a kind of tree) for medicinal purposes | ពាក្យនេះ សំដៅលើសកម្មភាព ដែលក្រុមបុរសៗជនជាតិកួយធ្លាប់បបួលគ្នីគ្នាចូលព្រៃដើម្បីទៅកាប់ដើមឈើភ្លើងយកទៅដំឲ្យហ្មត់ រួចហើយអូសនឹងទឹកធ្វើឲ្យទឹកនោះ មានសារជាតិពុលដែលត្រីក្នុងទឹកពុល អណ្ដែតឡើង បន្ទាប់មកក្រុមមនុស្សក៏មានភាពងាយស្រួលក្នុងការត្រងយក ឬវាយត្រីនឹងរំពាត់ដៃឬស្សីជាដើម។ |
| **បី/បេក/ឆាក់ចៀខ**<br> | ហ្មទាក់យកដំរី | Elephant keeper | ពាក្យនេះ សំដៅលើបុរសជនជាតិកួយដែលមានភាពប៉ិនប្រាសព្វក្នុងការទាក់ដំរី ជាពិសេសហ្មដំរីដែលមានចំណេះដឹងខាងមើលថែរក្សា និងឃ្វាលដំរី គាត់ចេះវិធីទាក់ដំរីបាន។ |
| **ប៉ាច់ ត្នាយ**<br>**ប៉ាច់ សូម** | ការកាប់ចុងផ្ដៅ<br>ឬចុងសោម | Trimming off the end of rattan vine | ពាក្យនេះគេប្រើលើគោលបំណងគឺ៖<br>នៅពេលជនជាតិកួយ ភាគច្រើនបុរសៗ (ភាគតិចជាស្ត្រី) ចូលព្រៃជ្រៅដើម្បីរកចុងសោម និងកាប់ចុងសោមយកទៅធ្វើជាម្ហូបអាហារ ដែល |

| | | | |
|---|---|---|---|
|  | | | ភាគច្រើនគឺពួកគាត់ទៅកាប់ជាក្រុមដោយប្រើសមត្ថភាព ក្នុងការទាញយកផលពីចុងសោម។ ពួកគាត់យកទៅធ្វើជាអាហារសាមគ្គី ឬអាហារក្នុងគ្រួសារក្នុងពេលមានកម្មវិធីប្រពៃណីរបស់សហគមន៍។ ពួកគាត់យល់ថា វាជាអាហារឧសថ ដែលជួយដល់សុខភាពរបស់ពួកគេ ហើយជួយដល់ពួកគេមានការទំនាក់ទំនងល្អ និងការផ្ទេរចំណេះដឹងតៗដល់កូនចៅ។ |
| **ប៊ុច ភួត**  | ជីកកង្កែប | Dig for frogs | ពាក្យនេះ ត្រូវបានប្រើប្រាស់ក្នុងពេលដែលជនជាតិកួយ ជាពិសសេស្រីៗ បបួលគ្នាទៅជីកកង្កែបនៅតាមមាត់អូរ ឬប្រឡាយជាពិសេសនៅរដូវវស្សានៅពេលលែលសត្វកកង្កែបទៅរស់នៅកប់ខ្លួនក្នុងដី ពួកគេជីកបានយកទៅធ្វើជាផ្អក ឬហាលទុកជាស្បៀងសម្រាប់ការងារពេលបង្កបង្កើនផល ពេលខ្លះពួកគេបានចែកចាយគ្នាហូបក្នុងភូមិ។ |
| **ប៊ឺរ ឡោម**  | ដើររកអណ្តើក | Find turtles | ពាក្យនេះ ជនជាតិកួយប្រើប្រាស់នៅរដូវប្រាំងនៅពេលដែលភ្លើងឆេះព្រៃ ជនជាតិកួយប្រើប្រាស់ចំណេះដឹងក្នុងរកអណ្តើក ដោយសារតែអណ្តើកលាក់ខ្លួនដើម្បីរក្សាសុវត្ថិភាពពីភ្លើងឆេះព្រៃ និងសត្វផ្សេងៗទៀតដែលយកពួកវាជាអាហារ។ សត្វអណ្តើកមានទំនៀមទម្លាប់របស់ពួកវានៅរដូវណាដែលត្រូវពង និងការរក្សាពងក្នុងរដូវដែលគេចខ្លួចពីភ្លើងឆេះព្រៃ។ ផ្អែកលើស្ថានភាពនេះ ជនជាតិកួយដែលមានការយល់ដឹងគឺពួកគាត់ត្រូវដឹងពីរបៀបក្នុងការរកសត្វអណ្តើក នៅពេលពួកគេបានអណ្តើកគឺគេយកទៅចិញ្ចឹមនៅភូមិដើម្បីត្រៀមលក់ និងទុកសម្រាប់បរិភោគតាមបែបប្រពៃណីពីបុរាណ។ ពួកគាត់យកអណ្តើកធ្វើ |

| | | | |
|---|---|---|---|
| | | | ជាអាហារសម្លកកូរជាមួយនឹងបន្លែព្រៃក្នុងកម្មវិធីបុណ្យភូមិ និងកម្មវិធីផ្សេងៗទៀតដែលរៀបចំឡើងដោយចាស់ទុំ។ |
| **ប៊ឺរ ម្យូល**  | ដើររកពង្រួល | Find pangolins | ពាក្យនេះ ជាប្រពៃណីត្រូវបានជនជាតិកួយប្រើប្រាស់ក្នុងពេលដែលពួកគេបបួលគ្នីគ្នាទៅដេកព្រៃចាប់ពីកន្លះខែចុះក្រោមជាមួយនឹងស្បៀងអាហារ។ ពួកគេទៅព្រៃអមដោយសត្វឆ្កែ និងសំភារៈជាមួយដោយប្រើប្រាស់ចំណេះដឹងពីរបៀបដែលសត្វពង្រួលលាក់ខ្លួនរស់នៅ និងពេលដែលសត្វពង្រួលចេញរកស៊ី។ ដើម្បីចាប់ពង្រួលបានជនជាតិកួយដែលជាមេក្រុមមានចំណេះដឹងត្រូវនិយាយឧបកិច្ចដើម្បីឲ្យបានសត្វពង្រួល។ នៅពេលបានពង្រួលគឺពួកគេត្រូវយកសាច់ចែកគ្នា និងធ្វើជាអាហារដោយចែកចាយបងប្អូនក្នុងភូមិ។ ការចាប់ពង្រួលគឺត្រូវប្រើប្រាស់ឧបករណ៍អង្គប់ធ្វើពីឬស្សីជាមួយនឹងវិធីសាស្ត្រដែលអាចចាប់បាន។ |
| **ប៊ឺរ ប៊ិច ចាំខ**  | ដើរជីកទំពាំង | Dig for bamboo shoots | ពាក្យនេះ ត្រូវបានជនជាតិកួយ (ស្ត្រី) តែងតែបបួលគ្នីគ្នាជាក្រុមទៅជីកទំពាំងនៅតាមព្រៃឬស្សី ឬស្សីនៅតាមមាត់ស្ទឹង មាត់អូរ មាត់ប្រឡាយ ដើម្បីយកទៅធ្វើម្ហូបអាហារដូចជា: ឆា ស្លប្រហើរ ស្លម្ជូរ ឬត្រាំជាទំពាំងជូរដើម្បីទុកបរិភោគនៅរដូវប្រាំង។ ក្រៅពីនេះ ពួកគាត់អាចលក់ទំពាំងបានថវិកាសម្រាប់ទិញសំភារៈកសិកម្ម ឬទិញគ្រឿងទេស។ |
| **ប៊ើក កោះ** *(តំបន់ក្រើ)* | ដើរព្រៃ | Go into the forest | ជាពាក្យដែលជនជាតិកួយប្រើក្នុងពេលសកម្មភាពទៅព្រៃដោយមានគ្នីគ្នាច្រើននាក់ មានទៅដោយសំភារៈដូចជា: អង្ករ ម្ហូប កាំបិត ពូថៅ ផ្កាក ។ល។ ដើម្បីដេកព្រៃច្រើនយប់នៅតាមព្រំប្រពៃណី និងនៅតាមតំបន់ |

| | | | |
|---|---|---|---|
| **ប៉ក អោះ**<br>*(តំបន់អ្វ័)*<br> | | | ដែលមានសត្វព្រៃ។ ពួកគាត់ក៏មានសត្វឆ្កែជាច្រើនក្បាលទៅជាមួយផងដែរ ដើម្បីសុវត្ថិភាពក្នុងព្រៃ។ នៅពេលពួកគាត់បានសត្វ ពួកគាត់មកភូមិវិញចែកចាយសាច់សត្វព្រៃជូនទៅបងប្អូនក្នុងភូមិធ្វើជាអាហារ និងមានកម្មវិធីហូប ផឹកស៊ីជុំគ្នាដោយសែនព្រេនចងអំបោះតាមដៃ (ជូរ៉ាយ) ហៅព្រលឹងវិញ្ញាណមកផ្ទះវិញ។ |
| **ប៊ឺរ លៀខ**<br> | រកគ្រំ ឬស្រវាគ្រំ | Find or feel for black mussels | ពាក្យនេះ ជាប្រពៃណីជនជាតិកួយប្រើនៅពេលដែលពួកគាត់បបួលគ្នាទៅស្រវ៉ាគ្រំនៅតាមស្ទឹងដែលមានទឹករាក់ៗ។ ពួកគាត់ទៅដោយមានគ្នាច្រើននាក់ ដោយសារតែវាមានចម្ងាយពីភូមិ។ ជាទូទៅពួកគាត់ចំណាយពេលពីរថ្ងៃដើម្បីបានគ្រំយកទៅធ្វើម្ហូបអាហារ។ ជាធម្មតាពួកគាត់ចែកចាយដល់សាចញាតិនៅក្បែផ្ទះបានហូបផងដែរ ប្រសិនបើគ្រួសារណាមួយមិនអាចទៅជាមួយបាន។ |
| **ប៊ូល ប្រណាក**<br> | បូលប្រណាក | Bol Pranak (a superstitious act of the local people to foresee something) | ពាក្យនេះ សំដៅលើសកម្មភាពគ្រូមើល គ្រូព្យាបាលជាបង់បត់។ ជាទូទៅស្ត្រីជនជាតិកួយដែលមានតួនាទីខាងកាន់រូប និងស្នងរូបជាអ្នកតាំងជំនឿ។ ពេលដែលកូនក្មេង ឬមនុស្សចាស់ឈឺថ្កាត់ខុសប្រក្រី គ្រូរូបត្រូវបានគេស្នើឲ្យបូលប្រណាក ដើម្បីរកខុសត្រូវ ឬបញ្ហាជាមួយដូនតា ឬខ្មោចក្នុងដី។ |
| **ប៊ូល ប្រែហ្លល ប្រ្ហូយ** | បូលដាក់ពង់មាន់ | Chanting with Chicken egg to foresee something through his superstition | ពាក្យនេះ ជនជាតិកួយ (ស្ត្រី) ប្រើប្រាស់ក្នុងកម្មវិធីបូលប្រណាកនៅពេលដែលនរណាម្នាក់មានជម្ងឺខុសពីធម្មតា ក្មេងយំមិនបាត់ ឬប្រផ្នូលមិនល្អជាដើម។ ស្ត្រីដែលតាំងរូបត្រូវបានគេរកឲ្យមើលតាមវិធី |

| | | | |
|---|---|---|---|
|  | | | ប្រពៃណីនៃការបួល។ គេអាចបួលពងមាន់ ឬបួលប្រណាក់ដោយមានដាក់អង្ករ ឬសំភារៈផ្សេងៗទៀត ហើយមានជាសំនួរ និងចម្លើយខ្លួនឯងដោយប្រើញាណ។ |
| **ប៊ិន ពៀរ ស្រ**  | បុណ្យផ្កាស្រូវ | Paddy rice festival | ពាក្យនេះសំដៅលើពិធីបុណ្យមួយដែលជនជាតិកួយ ជាប្រពៃណីតែងតែធ្វើប្រចាំឆ្នាំ ក្រោយពីការប្រមូលភោគផលស្រូវស្រែ និងស្រូវចម្ការ។ ពិធីបុណ្យនេះជនជាតិកួយតែងតែធ្វើនៅរដូវមាឃធំ ឬនៅតំបន់ខ្លះនៃជនជាតិកួយហៅថា ”បុណ្យមាឃផ្ការចារ” ដែលបុណ្យនេះជាកាតព្វកិច្ចរបស់សមាជិកគ្រប់រូបចូលរួមរហូតដល់ចប់កម្មវិធី។ |
| **បុក សយ អ្រូក់**  | ដកតាធៀង | Pick up Ta Theang (wild vegetable) | ពាក្យនេះសំដៅដល់សកម្មភាព ដែលជនជាតិកួយនៅក្នុងភូមិណាមួយបានបបួលគ្នីគ្នាចូលព្រៃដកបន្លែតាធៀង ដែលជាបន្លែព្រៃ។ ជាទូទៅបន្លែនេះមានដុះនៅក្នុងតំបន់ព្រៃរបោះ ឬព្រៃស្រោងនៅចន្លោះខែមេសាទៅខែមិថុនា។ ពួកគាត់ទៅរកបន្លែព្រៃជាក្រុមដើម្បីបានបន្លែព្រៃយកទៅបរិភោគ ដែលពួកគាត់យលថា បន្លែព្រៃនេះជាបន្លែឧសថ។ |
| **ឞាំខ លៃ**  | ទំពាំងខ្ចី | Short bamboo shoot | ពាក្យនេះ ជនជាតិកួយកំពុងតែប្រើប្រាស់តិចតួច ជាមួយនឹងសកម្មភាពប្រមូលផលទំពាំងខ្ចី ដោយសារតែទំពាំងខ្ចីបានថយចុះខ្លាំង និងកំពុងបាត់បង់ដោយសាកត្តាការផ្លាស់ដំណាំ និងតម្រូវការរបស់កសិករ។ ខ្ចីជាប្រភេទឬស្សីម្យ៉ាងដែលមានគុណប្រយោជន៍ចំពោះធម្មជាតិ មនុស្ស និងសត្វ និងអាចប្រើប្រាស់ធ្វើជាឧបករណ៍ផ្សេងៗ |

| | | | |
|---|---|---|---|
| **ធាំង ស្រង់**<br> | ទំពាំងឫស្សី | Bamboo shoot | ពាក្យនេះ សំដៅលើទំពាំងឫស្សី ដែលជាប្រភេទបន្លែព្រៃ ដែលជនជាតិកួយ ភាគច្រើនស្ត្រីតែងតែអាស្រ័យផលសម្រាប់ធ្វើបន្លែហូប និងលក់បានកម្រៃ។ ជនជាតិកួយចេះពីវិធីធ្វើទំពាំងស្ងោ ទំពាំងក្រៀមទុកហូបបានយូរ ទំពាំងជ្រក់ជាដើម។ |
| **ប៉ៀល ព្រែហ្ម តាក**<br> | ផ្កាអង្រែដែក | Angredeak flower (wild medicinal plant | ពាក្យនេះសំដៅលើផ្កាអង្រែដែកដែលមានដុះនៅក្នុងព្រៃសហគមន៍។ ផ្ការនេះគេអាចយកវាទៅផ្សំលាយជាមួយបន្លែផ្សេងៗទៀតក្នុងការធ្វើម្ហូប។ |
| **បុិច ត្លួត តោះ**<br> | ជីកត្នោតព្រៃ | Dig wild palm tree | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ នាំគ្នីគ្នាដោយវេចបាយនិងម្ហូបទៅព្រៃ ដើម្បីទៅរកត្នោតព្រៃ សម្រាប់យកទៅលក់បានប្រាក់កម្រៃ។ |
| **បុិ ប្រៀង**<br> | ជីកក្ដួច | Dig Kaduoch (a kind of wild potato) | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (ស្ត្រី) ទៅជីកក្ដួចយកទៅកែច្នៃជាអាហារមួយបែប ដែលមានរស់ជាតិជំនួសបាយបាន។ អាហារក្ដួចត្រូវបានស្ត្រីជនជាតិកួយអនុវត្តតាមចំណេះដឹង និងវិធីមួយចំនួនដើម្បីបន្សាបវាមិនអោយមានសារធាតុពុល ហើយអាចរក្សាទុកសម្រាប់ចំអិន ឬចំហុយបរិភោគបាន។ |

## អក្សរ ព

| | | | |
|---|---|---|---|
| **ពួយ ក្រាស**<br> | ដេញសត្វកង្ហែន | Chase striped squirrel away | នៅពេលអាកាសធាតុស្រទំ ឬក្រោយពីភ្លៀងធ្លាក់ដើមឆ្នាំ ដោយមានស្លឹកឈើលាស់ខ្ចី តាមប្រពៃណី ជនជាតិកួយ(បុរសៗ)តែងតែបបួលគ្នាទៅព្រៃឆ្ងាយពីភូមិ ជាមួយនឹងសត្វឆ្កែ។ ពួកគាត់បានដើរតាមគល់ឈើនិងបង្អៅឆ្កែរ។ នៅពេលមានសត្វកង្ហែនរត់ចូលរន្ធឈើ ពួកគាត់ចោះរន្ធឈើនោះដោយប្រើវិធីងាយៗ។ បើកង្ហែនចូលដំបូកពួកគាត់ត្រូវប្រើប្រាស់ចំណេះដឹងបំពក់កង្ហែន។ ក្រោយពីបានកង្ហែន ពួកគាត់យកទៅធ្វើម្ហូបហើយចែកចែកចាយគ្នា ឬបែងចែកសាច់កង្ហែនដល់គ្នាទៅវិញទៅមក។ |
| **ពួយ ត្លុខ**<br>**ពួយ ស្តេះ**<br> | ដេញចាប់សត្វស្វា | Chase monkeys | ពីបុរាណកាល នៅតាមចម្ការដែលមានម្ចាស់ច្រើននាក់ ពួកគាត់តែងតែធ្វើសកម្មភាពបណ្ដេញសត្វស្វា ឬធ្វើអន្ទាក់ចាប់ស្វាដើម្បីកុំឲ្យសត្វស្វាស៊ីដំណាំក្នុងចម្ការរបស់ពួកគាត់។ ពួកគាត់មានអារម្មណ៍ថាសត្វស្វាអាចនឹងចាប់ធ្វើបាបលើក្មេងស្រីបាន ឬមនុស្សស្រីបាន បើសិនជាមានស្វាច្រើន។ ដូច្នេះបុរសៗដែលមានកម្លាំង និងមានចំណេះដឹងខាងចាប់ស្វាត្រូវតែចាប់វាដើម្បីធ្វើជាម្ហូបអាហារ។ ពេលខ្លះពួកគាត់ចាប់សត្វស្វាយកទៅចិញ្ចឹមដាក់ទ្រុង ឬចងខ្សែរដើម្បីការពារនៅផ្ទះសម្បែង និងអាចធ្វើឲ្យអ្នកក្នុងភូមិចោមរោមគ្នាទៅមើលផងដែរ។ |
| **ពួយ លឹក គោះ** | ដេញជ្រូកព្រៃ | Chase boars away | សំដៅលើសកម្មភាពរួមរបស់ជនជាតិកួយពីបុរាណ។ នៅក្នុងភូមិមួយដែលពួកគេបានបបួលគ្នីគ្នាទៅដេញជ្រូកព្រៃហ្វូង និងជ្រូកព្រៃដែលបំផ្លាញដំណាំក្នុងចម្ការ ឬដំណាំក្នុងស្រែរបស់អ្នកស្រុក។ ក្នុងការដេញជ្រូក មានព្រានព្រៃដែលមានចំណេះដឹង និងមានសមត្ថភាពក្នុងការធ្វើ |

| | | | |
|---|---|---|---|
|  | | | ឲ្យបានជ្រូកព្រៃ។ ព្រានព្រៃ ត្រូវតែណែនាំដល់កូនព្រានពីរបៀបរក្សាសុត្ថិភាពជីវិត និងក្បួនដែលជ្រូកព្រៃរបួសរត់មករកមនុស្សដើម្បីវៀសនឹងចង្កូមវា កូនព្រានត្រូវដឹងពីរបៀបប្រុងប្រយ័ត្នខ្ពស់នៅពេលដែលជ្រូកមានរបួសស្នាមខ្លាំង។ |
| **ពួយ ត៊ឹរ**  | ដេញឆ្មាបា | Chase flying lemur away | កាលពីបុរាណ ជនជាតិកួយប្រើពាក្យនេះ ក្នុងពេលដែលពួកគាត់មានគ្នាចាប់ពីពីរនាក់ឡើងទៅ ដើម្បីទៅរកសត្វឆ្មាបាដែលលាក់ខ្លួននៅតាមរន្ធឈើក្នុងព្រៃធំ។ ពួកគាត់ ប្រើប្រាស់វិធីសាស្ត្រប្រពៃណីដូចជាបំពក់ភ្លើងក្នុងមាត់រន្ធ គស់ប្រហោងឲ្យលឿសម្លេងខ្លាំងៗដើម្បីឲ្យវាហើរចេញមក បន្ទាប់មកពួកគាត់ប្រើវិធីសាស្ត្រចាប់យកដោយប្រុងប្រយ័ត្ន។ |
| **ធ្លើ ហុខ**  | ក្បាលជាំ | Bruised head | ពាក្យនេះ សំដៅលើព្រៃដែលមានជាំ (ទឹក) ទឹកនៅក្រោម ស្មៅ និងដើមឈើដុះពីលើ ការដើរត្រូវប្រុងប្រយ័តក្រែងមានសត្វក្រពើនៅក្រោម ឬអាចផុងធ្លាក់ចូលទៅក្រោមបាន។ |
| **ពូច ប្រស់ ត្លូខ** *(តំបន់ផ្អើ)* **ម៉ូច ប្រស់ត្លូខ** *(តំបន់អ្វ័)* | ដកប្រ៉េស់ស្វា | Pick up aromatic ginger | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (ស្រ្តី) តែងតែនំគ្នាទៅដកស្លឹកព្រះស្វានៅតាមក្បាលស្រែ ឬតាមចម្កាចាស់ ឬនៅតាមទីតាំងដែលស្លឹកនេះលាស់ក្នុងរដូវដើមឆ្នាំ បន្ទាប់ពីមានភ្លៀងធ្លាក់ជាច្រើនមេ។ គេយកវាទៅញាំជាមួយអង្រ្កង ឬស្លក៍បាន។ |



## អក្សរ ទ

| | | | |
|---|---|---|---|
| **ទ៉ ធ្នេះ**<br>**ទ៉ ត្រើខ**<br> | ធ្វើធ្នោះ ឬធ្វើត្រើងធ្នោះ | Make thnuos (fishing equipment) | ពាក្យនេះ ត្រូវបានជនជាតិកួយប្រើប្រាស់ក្នុងសកម្មភាពធ្វើថ្នុះដើម្បីចាប់ត្រីនៅរដូវវស្សា។ ពួកគាត់ប្រើប្រាស់ចំណេះដឹងខាងធ្វើថ្នុះជាក្រុម។ មនុស្សក្នុងក្រុមនេះ គេបែងចែកការងារគ្នាធ្វើទៅតាមសមត្ថភាព រួចពួកគាត់ធ្វើការរួមគ្នា។ ទីតាំងនៃថ្នុះត្រូវធ្វើឲ្យរឹងមាំ ដើម្បីទប់ទប់កុំអោយទឹកវ៉ៃខ្លាំង ពីព្រោះអាចប៉ើងថ្នុសទៅតាមកម្លាំងទឹកហូរបាន។ ពួកគាត់អាចរកត្រីបានពីថ្នុះនេះក្នុងមួយរដូវវស្សាទឹកធំ។ |
| **ទ័ ច្លុះ ថិត**<br> | ធ្វើចន្លុះដុត | Make Chanlosh (natural torch) | ជនជាតិកួយពីបូរាណ ធ្វើចន្លុះសម្រាប់បំភ្លឺផ្ទះ ខ្ទមស្រែ ខ្ទមចម្ការ និងដុតបំភ្លឺក្នុងកម្មវិធីប្រពៃណីផ្សេងៗទៀត។ ពួកគាត់ធ្វើវាពីជ័រទឹកលាយជាមួយស្លឹកព្រាល ឬសំបកផ្សេងៗទៀត។ ការទៅរកស្លឹកព្រាលធ្វើចន្លុះពួកគាត់ត្រូវទៅគ្នាច្រើនដើម្បីសុវត្ថិភាពក្នុងការធ្វើដំណើរ។ |
| **ទ័ អ្គឹប ពឹត** | ធ្វើអង្គប់ធំ | Make big traps | សំដៅដល់សកម្មភាពពីបុរាណដែលជនជាតិកួយធ្វើអង្គប់ដៃ ឬអង្គប់ធំដើម្បីបានសត្វជាអាហារ។ ជនជាតិកួយប្រើប្រាស់ចំណេះដឹងក្នុងការធ្វើអង្គប់ដោយប្រើប្រាស់កូនឈើក្នុងព្រៃ និងការបួងសួង ឬក្ងកព្រៃទៅ |

| | | | |
|---|---|---|---|
|  | | | ដល់អារក្សព្រៃដើម្បីសុំសត្វព្រៃ នៅពេលដែលពួកគាត់បានសត្វព្រៃ ពួកគាត់បានយកសាច់សត្វទៅចែកគ្នាធ្វើជាអាហារ និងមួយចំណែក ពួកគាត់ដុត ឬអាំងហូបភ្លែមរួមគ្នា និងមានកកម្មវិធីរាំកំសាន្តជាមួយគ្នា។ |
| **ទ៉ាច អ្រៀល ត្រខ**  | កាយពងត្រង | Find iguana eggs | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ ជាពិសេសបុរសមានចំណេះដឹងពីការកាយរកពងត្រង។ |
| **ទ័ អ្លាប់ កោះ** | ធ្វើរង្គប់យកសត្វ | Make traps for animals hunting | ពាក្យនេះសំដៅលើសកម្មភាពពីបុរាណ ដែលជនជាតិកួយ ជាទូទៅរស់នៅក្បែព្រៃ តែងតែនាំគ្នាជាក្រុមទៅធ្វើរង្គប់នៅមាត់ព្រៃ ឬព្រៃជ្រៅដើម្បីយកសត្វតាមប្រភេទផ្សេងៗយកទៅធ្វើជាអាហារតាមប្រពៃណី។ ដោយសារតែនៅក្នុងព្រៃធំ ឬព្រៃជ្រៅគឺសម្បូរទៅដោយសត្វច្រើន និងសត្វសាហាវផងដែរ ដូច្នេះ ព្រានព្រៃតែងតែប្រើមន្តអាគមដើម្បីឧបកិច្ចជាមួយអ្នកតាម្ចាស់ព្រៃ គឺសុំឲ្យបានសត្វ និងកុំឲ្យមានគ្រោះថ្នាក់ដល់មនុស្សក្នុងក្រុម ហើយពេលបរិភោគសាចជាអាហារសុំឲ្យអ្នកស្រុកមានសេចក្ដីសុខ ចំរុងចំរើន។ |

## អក្សរ ស

| | | | |
|---|---|---|---|
| **សេន កន ចៅ** | សែនកូនចៅ | | ពាក្យនេះ សំដៅលើពិធីដែលជនជាតិកួយធ្វើការសែនព្រែនដល់កូនចៅនៅពេលដែលស្ត្រី ឬបុរសស្រឡាញគ្នា ឬពួកគេទាំងពីរនាក់បានធ្វើ |

OPKC

| | | | |
|---|---|---|---|
|  | | | អ្វីមួយជាការខុសឆ្គងប្រពៃណី ដោយក្រែងខុសនឹងដូនតា ចាស់ទុំត្រូវរៀបចំសែនព្រេន។ |
| **សេន ភ្ទូច**  | សែនផ្តាច់ខ្មោច | Ritual of expelling evil spirits | ពាក្យនេះប្រើសំដៅលើគ្រួសារដែលមានសមាជិកស្លាប់ គឺគេហៅបងប្អូនសាច់បង្កើត ឬសាច់ថ្លៃមកអង្គុយតម្រៀបគ្នាជាជួរ រួចឲ្យកាន់សំភារៈណាមួយ ហើយពោលពាក្យតាមចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ដោយនិយាយតាមគាត់ក្នុងការពោលពាក្យសុំខមាទោស និងសុំអហោសិកម្ម កុំឲ្យវិលវល់ និងសុំឲ្យទៅបានសុខកន្លែងភពថ្មី។ |
| **សោះ ចូស យ៉ាក់**  | ឡើងអ្នកតា | To get together and pray for something | ពាក្យនេះសំដៅលើ សកម្មភាពដែលជនជាតិកួយទូទាំងសហគមន៍បានព្រមព្រៀងគ្នាប្រារព្ធពិធីឡើងដូនតា ឬអ្នកតាចាស់ស្រុកជាប្រចាំឆ្នាំ ដើម្បីលាបំណន់ ថ្វាយអាហារទាំងបី និងបួងសួងសុំសេចក្តីសុខឆ្នាំថ្មី។ |
| **សេន ជូស យ៉ាក់**  | សែនដូនតា | Hold an ancestral spirit ceremony | ពាក្យនេះប្រើសំដៅលើ សកម្មភាពរបស់ជនជាតិកួយធ្វើពិធីសែនព្រេននៅពេលដែល មានគ្រួសារថ្មីឡើងផ្ទះ បង្កក់សេរី បង្កក់កូន ឬលាបំណន់ជាដើម ដើម្បីសុំសេចក្តីសុខ សេចក្តីចំរើន។ |
| **ស្រាក់ ភ្លួ**  | រាវខ្យង | Hunt snails | ពាក្យនេះសំដៅលើសកម្មភាពដែលជនជាតិកួយជាពិសេសក្មេងៗ ឬស្ត្រីៗតែងតែរាវខ្យងនៅតាមស្រែ នៅរដូវវស្សានៅតាមស្រែដែលមិនទាន់ភ្ជួរ ឬស្រែដែលភ្ជួរត្រៀមស្ទូង ដើម្បីកុំអោយខ្យងកាត់សន្ទូង និងដើម្បីយកខ្យងធ្វើជាម្ហូបអាហារ។ |

## អក្សរ អ

| | | | |
|---|---|---|---|
| **អារ់ ឈ័ខ**<br> | អារឈើ | Saw/cut the wood | ពាក្យនេះសំដៅលើសកម្មភាពជនជាតិកួយ ជាពិសេសក្រុមបុរសដែលមានចំណេះដឹងខាងគ្រឿងឈើ ចំណេះដឹងខាងជាងឈើ និងស្គាល់ពីប្រភេទឈើ ព្រមទាំងស្គាល់ទីតាំងដែលមានដើមឈើសម្រាប់ទៅអារ។ ការងារអារឈើ តម្រូវឲ្យមានគ្នាជាក្រុមដើម្បីមានសមត្ថភាព ឬលទ្ធភាពទាញយកគ្រឿងឈើបាន ពួកគាត់ជួយគ្នាក្នុងការអារឈើ និងប្រើប្រាស់ការបង្កើតគំនិតថ្មី។ |
| **អែល យ៉ាក់ គឺ**<br> | យកទល់ | Keep it from falling | ពាក្យនេះ សំដៅលើសកម្មភាពរបស់ស្ត្រីជនជាតិកួយដែលតែងតែទៅកាប់ទាល់ដែលមានដុះតាមព្រៃ ក្នុងគោលបំណងយកទៅស្លប្រហើរ ឬចំអិនអាហារសម្រាប់ការចិញ្ចឹមជ្រូកស្រុក។ |
| **អែល តី ច្រូត ស្រ**<br> | ច្រូតស្រូវយកដៃគ្នា | Mutual aid harvesting | សំដៅដល់សកម្មភាព ដែលជនជាតិកួយក្នុងភូមិណាមួយបានព្រមព្រៀងគ្នាក្នុងការច្រូតស្រូវស្រែ ឬស្រូវចម្ការរួមគ្នា ជួយគ្នាដោយមិនប្រើប្រាស់ថ្លៃឈ្នួល ដែលមានអត្ថប្រយោជន៍ប្រមូលផលស្រូវឆាប់ហើយ ឬផ្តល់ជាកម្លាំងចិត្តដល់គ្នា រក្សាបានសាមគ្គីភាព ធ្វើឲ្យពួកគាត់មានភាពក្លាហាន។ |

| | | | |
|---|---|---|---|
| **អែល ខៀល**<br> | យកឃ្មុំ | Harvest honey from bees | ពាក្យនេះសំដៅលើ សកម្មភាពជនជាតិកួយដែលរស់នៅក្បែរព្រៃធំ និងក្បែរព្រៃភ្នំ។ ជាប្រពៃណី បុរសៗដែលមានចំណេះដឹង និងជំនាញក្នុងការយកឃ្មុំលើដើមឈើធំៗ ពួកគាត់ត្រូវបែងចែកមនុស្សក្នុងក្រុមដើម្បីយកឃ្មុំបាន។ ក្រោយពីយកឃ្មុំបាន ពួកគាត់ធ្វើការបែងចែកផលប្រយោជន៍ដល់គ្នា។ មួយផ្នែកទៀតពួកគាត់ដាក់ជារបស់រួមនៅពេលលក់បានលុយគឺពួកគាត់បែងចែកកម្រៃស្មើៗគ្នា។ ក្រៅពីនេះពួកគាត់ចាត់ចែងកូនឃ្មុំជាអាហារ ទឹកឃ្មុំសម្រាប់បរិភោគឬលក់ ព្រមទាំងយកក្រមួនឃ្មុំទៅចម្រាញ់ដើម្បីប្រើប្រាស់ជាមធ្យោបាយផ្សេងៗទៀតក្នុងកម្មវិធីប្រពៃណី។ |
| **អែល ហាខ**<br> | យកឪម៉ាល | Obtain larvae from a wasp nest | ពាក្យនេះសំដៅលើ សកម្មភាពក្រុមបុរសជនជាតិកួយ បាននាំគ្នីគ្នាទៅយកឪម៉ាលតាមវាល ឬតាមព្រៃរបោះ។ ពួកគាត់ប្រើប្រាស់ចំណេះដឹងខ្ពស់ក្នុងការយក ដោយសារវាជាសត្វមានទ្រនិចនិងពិសខ្លាំង។ ពួកគាត់ដុតជាមួយស្លឹកបំពក់ពីខាងក្រោមឲ្យមានផ្សែង រួចហើយពួកគាត់ឡើងកាត់សំបុកទំលាក់ចុះក្រោម ហើយយកកូនឬពងឪម៉ាលដែលនៅតាមក្រាសនៃសំបុក។ ពួកគាត់យកកូនឬពងវាធ្វើជាអាហារផ្សំជាមួយគ្រឿងទេសផ្សេងៗទៀតបង្កើតបាននូវរស់ជាតិឆ្ងាញ់។ |
| **អែល បាំខ ស្រខ/ បាំខលៃ**<br> | យកទំពាំងឬស្សី ឬទំពាំងខ្លី | Harvest bamboo shoots | ពាក្យនេះសំដៅសកម្មភាពដែលជនជាតិកួយ ទាំងស្ត្រី និងបុរសនាំគ្នាទៅកាច់ទំពាំងដែលមានដុះនៅតាមដងអូរ តាមស្ទឹង ឬតាមប្រឡាយដើម្បីយកទៅធ្វើជាបន្លែដែលអាចហូបបានភ្លាមៗ ឬទុកហូបបានយូ ឬអាចទុកលក់បានជាប្រាក់ចំណូល។ |

OPKC

សម្របសម្រួល និងចងក្រងដោយ

**លោក ហ៊ីង ម៉ុនណាត**

**អ្នកស្រាវជ្រាវ** OPKC

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤

ឃ OPKC

សូមអរគុណដល់ម្ចាស់មូលនិធិ

និងសូមអរគុណដល់មិត្តអ្នកអាន!

សំណាងល្អ និងជោគជ័យគ្រប់ភារៈកិច្ច!